# កិច្ចប្រជុំត្រួតពិនិត្យការអនុវត្តប្រចាំត្រីមាស (QPRM)

មជ្ឈមណ្ឌលជាតិកំចាត់រោគ របេង និង ឃ្លង់
National Center for Tuberculosis and Leprosy Control (CENAT)

USAID FROM THE AMERICAN PEOPLE

TB DIAH

## អ្វីទៅជាការប្រជុំត្រួតពិនិត្យប្រចាំត្រីមាស?

កិច្ចប្រជុំត្រួតពិនិត្យប្រចាំត្រីមាស គឺជាការជួបជុំប្រចាំត្រីមាសដែលអ្នកអភិបាលរបេងស្រុកប្រតិបត្តិ និងបុគ្គលិកមូលដ្ឋានសុខាភិបាល និងអ្នកតំណាងពីខាងអង្គការអនុវត្តកម្មវិធីរបេង និងអ្នកសហគមន៍ ដើម្បីធ្វើការពិនិត្យទៅលើការអនុវត្តកម្មវិធីរបេង និងការអនុវត្តផ្ទាល់ខ្លួននៅក្នុងស្រុកប្រតិបត្តិ ក្នុងការបញ្ចប់ជំងឺរបេង និងការឆ្ពោះទៅការសម្រេចបាននូវគោលដៅជាតិ និងគោលដៅស្រុកប្រតិបត្តិ។

## អ្នកណាខ្លះចូលរួមក្នុងកិច្ចប្រជុំពិនិត្យប្រចាំត្រីមាស?

- អ្នកអភិបាលរបេងស្រុកប្រតិបត្តិ (អ្នកដឹកនាំប្រជុំ)
- អ្នកទទួលបន្ទុកកម្មវិធីរបេងនៅមូលដ្ឋានសុខាភិបាល
- ដៃគូអនុវត្តកម្មវិធីរបេង
- ដៃគូផ្សេងទៀត-សហគមន៍-អង្គការមិនមែនរដ្ឋាភិបាល

## តើការប្រជុំត្រួតពិនិត្យការអនុវត្តប្រចាំត្រីមាសមានគោលបំណងអ្វី?

កិច្ចប្រជុំត្រួតពិនិត្យប្រចាំត្រីមាស បានផ្តល់ការត្រួតពិនិត្យលើអនុវត្តកម្មវិធីរបេងលក្ខណ:ស្តង់ដារនៅតាមស្រុកប្រតិបត្តិ។ គឺការប្រើប្រាស់ដែលជំរុញទិន្នន័យទៅលើ៖

→ ពិនិត្យគុណភាពទិន្នន័យរបេង
→ ប្រើប្រាស់ទិន្នន័យរបេងសម្រាប់វិភាគលើការអនុវត្តកម្មវិធីរបេង
→ កំណត់គំលាតនៃការអនុវត្ត ដោយប្រើប្រាស់សូចនការរបេងគន្លឹះ
→ ពិភាក្សាឫសម្ងលេហតុនៃបញ្ហាគុណភាពទិន្នន័យ និងគំលាតនៃការអនុវត្ត
→ សម្រេច និងតាមដានសកម្មភាពដែលបានដាក់ឡើងដើម្បីពង្រឹងគុណភាពទិន្នន័យ/គំលាតនៃកម្មវិធី

## ការត្រៀមរៀបចំកិច្ចប្រជុំ?
## ប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់នេះ៖

- [x] កំណត់អ្នកចូលរួមក្នុងកិច្ចប្រជុំ
- [x] ពិនិត្យ និងធ្វើបច្ចុប្បន្នភាពគុណភាពទិន្នន័យ និងបង្កើតផ្ទាំងរូបភាពទិន្នន័យ
- [x] បង្កើតរបៀបវ: និងចែកចាយ
- [x] រៀបចំសូចនាករនៃការអនុវត្តកម្មវិធីរបេង និងផ្ញើជូនអ្នកចូលរួមក្នុងកិច្ចប្រជុំ

TB DQ Checklist: Standard Operating Procedure

TB DQ Checklist: Guide for TB OD Supervisor

# កិច្ចប្រជុំត្រួតពិនិត្យការអនុវត្តប្រចាំត្រីមាស (QPRM)

មជ្ឈមណ្ឌលជាតិកំចាត់រោគ របេង និង ឃ្លង់
National Center for Tuberculosis and Leprosy Control (CENAT)

## គំរូរបៀបវារៈ

1. កិច្ចស្វាគមន៍ និងសេចក្ដីផ្ដើម
2. បច្ចុប្បន្នភាព-ដោយផ្ដោតលើការសម្រេចកាលពីប្រជុំមុនៗ
3. របកគំហើញពីការត្រួតពិនិត្យគុណភាពទិន្នន័យ-បង្ហាញផ្ទាំងរូបភាពទិន្នន័យ កំណត់ពីបញ្ហាបើមាន និងការសម្រេចលើសកម្មភាពដើម្បីដោះស្រាយបញ្ហាគុណភាពទិន្នន័យ
4. មូលដ្ឋានសុខាភិបាលបង្ហាញពីសូចនាកររបេង
5. ពិភាក្សាលើមូលហេតុគម្លាតនៃការអនុវត្ត បើមាន
6. សកម្មភាពដោះស្រាយគម្លាត ធនធានដែលត្រូវការ និងអង្គភាព/បុគ្គលិកដែលទទួលខុសត្រូវ

## ក្រោយកិច្ចប្រជុំ-បញ្ជីផ្ទៀងផ្ទាត់

- [x] រួមកំណត់ត្រាពីកិច្ចប្រជុំ និងផ្ញើទៅអ្នកបានចូលរួមទាំងអស់ក្នុងអំឡុង១សប្ដាហ៍ក្រោយប្រជុំ។
- [x] បន្តតាមដានជាមួយលមូលដ្ឋានសុខាភិបាលពីសកម្មភាពដែលបានដាក់ចុះក្នុងពេលប្រជុំ
- [x] កើនរំលឹកកិច្ចប្រជុំបន្ទាប់

## កិច្ចប្រជុំនឹងបង្ហាញ៖

### ផ្ទាំងរូបភាពគុណភាពទិន្នន័យ (ជាឧទាហរណ៍)



### វិមាត្រគុណភាពទិន្នន័យ៖

- ភាពពេញលេញនៃរបាយការណ៍
- ភាពទាន់ពេលវេលានៃរបាយការណ៍
- ភាពពេញលេញនៃសូចនាករទិន្នន័យ
- ការផ្ទៀងផ្ទាត់ទិន្នន័យឲ្យមានភាពសុក្រឹត្យ
- ភាពស៊ីគ្នាផ្នែកក្នុង-តាមពេលវេលា

### សូចនាករការអនុវត្តរបេងទូទៅដែលត្រូវបានពិនិត្យក្នុងពេលប្រជុំត្រីមាស៖

- ចំនួនរបេងចុះបញ្ជីព្យាបាល
- ចំនួនរបេងសួត
- ចំនួនធ្វើតេស្តដោយប្រើ geneXpert
- ចំនួនករណីវិជ្ជមានភាពស៊ាំថ្នាំ rifampicin
- ចំនួនករណីរបេងសួតធ្វើរោគវិនិច្ឆ័យគ្លីនិក
- ចំនួនអ្នករស់នៅជិតស្និទ្ធដែលទទួលការព្យាបាលបង្ការ
- ចំនួនអ្នកជំងឺរបេងមានHIV

TB DQR Tool and Dashboard

### ផ្ទាំងរូបភាពទិន្នន័យនៃការអនុវត្តសូចនាកររបេង (ជាឧទាហរណ៍)




This publication was produced with the support of the United States Agency for International Development (USAID) under the terms of the TB Data, Impact Assessment and Communications Hub (TB DIAH) Associate Award No. 7200AA18LA00007. TB DIAH is implemented by the University of North Carolina at Chapel Hill, in partnership with John Snow, Inc. Views expressed are not necessarily those of USAID or the United States government. SR-23-194c KH TB